**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ........ ..........

ថ្ងៃ................ខែ..........ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..........ឆ្នាំ២០២០

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ក្ល័រឧស្ម័ន សម្រាប់ប្រព្រឹត្តិកម្មទឹកស្អាត។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ត្រឹមវេលាម៉ោង ១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ៦០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ១៤:០០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) អាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**អគ្គនាយក**

**ស៊ឹម ស៊ីថា**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh